00598662

D390/1/2/1

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 06 / 09 / 2010
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

# នៅចំពោះមុខអង្គបុរេជំនុំជម្រះ
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ71)

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គបុរេជំនុំជម្រះ

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ២០១០

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ

ប្រភេទចំណាត់ថ្នាក់ឯកសារ

ការពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 07 / 09 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

---

# បណ្ដឹងឧទ្ធរណ៍ជាបន្ទាន់របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្ដីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារឆ្លើយតបរបស់ លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ និងសេចក្ដីសង្កេតបន្ថែម និង សំណើសុំផ្អាកដំណើរការនីតិវិធី

---

**ដាក់ដោយ៖**

**សហមេធាវី:**

លោក អាង ឧត្ដម

លោក Michael G. KARNAVAS

**ផ្ញើជូន៖**

**អង្គបុរេជំនុំជម្រះ**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម ន័យ ថុល

ចៅក្រម ហួត វុទ្ធី

ចៅក្រម Catherine MARCHI-UHEL

ចៅក្រម Rowan DOWNING

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្ដីទាំងអស់**

លោក អៀង សារី តាមរយៈសហមេធាវីការពារក្តីរបស់គាត់ (“មេធាវីការពារក្តី”) ដោយអនុលោមតាមវិធាន២១(១) នៃវិធានផ្ទៃក្នុង(“វិធានផ្ទៃក្នុង”) សូមដាក់ជូននូវបណ្តឹងឧទ្ធរណ៍ជាបន្ទាន់ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារ (“សេចក្តីសម្រេចដែលគេជំទាស់តវ៉ា”[1]) ចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន ៦៦ និងសេចក្តីសង្កេតបន្ថែម (“ចម្លើយតប”[2])។ បណ្តឹងឧទ្ធរណ៍ជាបន្ទាន់នេះត្រូវធ្វើឡើងជាចាំបាច់ ដោយសារតែកសចស បានរំលោភបំពានសិទ្ធិជាមូលដ្ឋានរបស់លោក អៀង សារី រួមមាន៖ ក) សមភាពនៃមធ្យោបាយតទល់ក្តី ដោយអនុញ្ញាតអោយការិយាល័យសហព្រះរាជអាជ្ញា (“កសព”) ដាក់ដីកាសន្និដ្ឋានស្ថាពរដែលមានកម្រាស់ ៩៣១ ទំព័រ ដែលមានរៀបរាប់អំពីអ្វីដែល កសព យល់ឃើញថាជាច្បាប់ដែលអាចយកមកអនុវត្តបាន ខណៈពេលនោះបានបដិសេធសិទ្ធិមេធាវីការពារក្តី មិនអោយដាក់ចម្លើយតបពេញលេញ ដែលចម្លើយតបនេះមានកម្រាស់ ៦៦ ទំព័រ, ខ) ការប្រព្រឹត្តមកលើដោយស្មើភាពគ្នាចំពោះមុខច្បាប់ ដូចដែលបានបង្ហាញជូនតាមរយៈការប្រៀបធៀបការប្រព្រឹត្តរបស់ កសចស មកលើ កាំង ហ្កេកអ៊ាវ នៅក្នុងសំណុំរឿង ០០១ ជាមួយនឹងការប្រព្រឹត្តមកលើមេធាវីការពារក្តីនៅក្នុងសេចក្តីសម្រេចដែលគេជំទាស់តវ៉ា និង គ) សិទ្ធិក្នុងការត្រៀមរៀបចំកិច្ចការពារក្តីអោយបានពេញលេញ និងចងក្រងបង្កើតនូវទិន្នន័យតាមការរយៈការបដិសេធមិនដាក់ចម្លើយតបទៅក្នុងសំណុំរឿង ។ ដើម្បីគោរពសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់លោក អៀង សារី ចម្លើយតបរបស់គាត់ត្រូវតែដាក់ចូលទៅក្នុងសំណុំរឿង ហើយទទួលបានការពិចារណាដំណាលគ្នានឹងដីកាសន្និដ្ឋានស្ថាពរ អនុលោមតាមវិធាន ៦៦ របស់ សហព្រះរាជអាជ្ញា (“ដីកាសន្និដ្ឋានស្ថាពរ”)[3] ។ ការផ្អាកនីតិវិធីគឺជាការចាំបាច់ ដើម្បីជៀសវាងភាពអយុត្តិធម៌ជាក់ស្តែង។ សូមស្នើអោយមានសវនាការជាសាធារណៈ ដើម្បីបង្កើតបន្ថែមអោយបានពេញលេញ និងមានតម្លាភាពនូវអំណះអំណាងនានាដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍នេះ។

---

[1] *ករណី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ការជូនដំណឹងអំពីការដាក់ឯកសារមិនគ្រប់គ្រាន់របស់ក្រឡាបញ្ជី កសចស ចុះថ្ងៃទី ២ កញ្ញា ២០១០។ *សូមមើល* **ឧបសម្ព័ន្ធ ១** ។

[2] *ករណី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់ កសព អនុលោមតាមវិធាន ៦៦ និងសេចក្តីសង្កេតបន្ថែម ចុះថ្ងៃទី ១ កញ្ញា ២០១០ ។ **ឧបសម្ព័ន្ធ ២** ។

[3] *ករណី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ដីកាសន្និដ្ឋានស្ថាពររបស់ កសព អនុលោមតាមវិធាន ៦៦ ចុះថ្ងៃទី ១៦ សីហា ២០១០ ឯក*ករណី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ឯកសារលេខ D390, ERN: 00591062-00591992។

## I. បញ្ហាបឋម

### ក. ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍នេះ

១. បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបានអនុលោមទៅតាមវិធាន ២១។ វិធាន ២១ ចែងថា៖

> ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និង បទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍ ... ជនត្រូវចោទ។ ទាក់ទងនឹងចំណុចនេះ៖ ក-ដំណើរការនីតិវិធីក្នុងអង្គជំនុំជម្រះវិសាមញ្ញត្រូវតែមានយុត្តិធម៌ និង ត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ ។ ... ខ-បុគ្គលទាំងឡាយដែលរកឃើញថា ស្ថិតនៅក្នុងស្ថានភាពស្រដៀងគ្នា និង ត្រូវបានចោទប្រកាន់ចំពោះបទល្មើសដូចគ្នា ត្រូវយកវិធានដូចគ្នាមកអនុវត្ត។ ឃ-ជនណាដែលត្រូវបានសង្ស័យ ឬ ត្រូវបានចោទប្រកាន់ ... មានសិទ្ធិ ... មានមេធាវីការពារ ...[4] ។

២. អង្គបុរេជំនុំជម្រះ កាលពីលើកមុនបានថ្លែងថា ទាក់ទងនឹងយុត្តាធិការរបស់ខ្លួន អង្គបុរេជំនុំជម្រះ "នឹងពិនិត្យថាតើវិធាន ២១ តម្រូវថា អង្គបុរេជំនុំជម្រះត្រូវធ្វើការបកស្រាយអោយបានទូលំទូលាយនូវសិទ្ធិរបស់ជនត្រូវចោទ ក្នុងការប្តឹងឧទ្ធរណ៍ដើម្បីធានាថា នីតិវិធីនៅក្នុងដំណាក់កាលស៊ើបសួរមានយុត្តិធម៌ និងចំពោះមុខ ហើយរក្សាបាននូវតុល្យភាពនៃសិទ្ធិរបស់ភាគី"[5]។ ដូច្នេះវិធាន ២១ ជជែកអំពីយុត្តាធិការដែលមានជាប់មកជាមួយរបស់ អង្គបុរេជំនុំជម្រះ ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ទាក់ទងទៅនឹងសិទ្ធិរបស់ជនត្រូវចោទ ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌។ អង្គបុរេជំនុំជម្រះ មានយុត្តាធិការដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នេះ ដោយសារបណ្តឹងឧទ្ធរណ៍

---

[4] គូសបញ្ជាក់បន្ថែម ។

[5] *ករណី ខៀវ សំផន* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ១១) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី ២០ កុម្ភៈ ២០០៩ឯកសារលេខ A190/I/20, ERN: 00283249-00283262 កថាខណ្ឌ ៣៦។ *សូមមើលផងដែរ រឿងក្តី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ៦៤) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ សហចៅក្រមស៊ើបអង្កេត បដិសេធសំណើសុំអនុញ្ញាតអោយមានការថតសម្លេង និងរូបភាពវីដេអូនៃកិច្ចប្រជុំជាមួយ អៀង សារី នៅមន្ទីរឃុំឃាំង ចុះថ្ងៃទី ១១ មិថុនា ២០១០ ឯកសារលេខ A371/2/12, ERN: 00531173-00531191 កថាខណ្ឌ ១៣-១៤។

នេះទាក់ទងទៅនឹង សិទ្ធិជាមូលដ្ឋានរបស់លោក អៀង សារី ក្នុងការទទួលបានសមភាពនៃមធ្យោបាយតទល់ក្តី ការប្រព្រឹត្តមកលើដោយស្មើភាពគ្នាចំពោះមុខច្បាប់ និងសិទ្ធិក្នុងត្រៀមរៀបចំកិច្ចការពារក្តី ។

**ខ. សំណើសុំផ្អាកដំណើរការនីតិវិធី**

៣. ទាំងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឬវិធានផ្ទៃក្នុងមិនបានចែងអំពីលក្ខខណ្ឌតម្រូវចាំបាច់ដើម្បីផ្អាកដំណើរការនីតិវិធីនោះទេ ។ ប៉ុន្តែ កសចស បានថ្លែងថាសហចៅក្រមស៊ើបអង្កេត "ពិចារណាថាគោលការណ៍ច្បាប់ដែលអនុវត្តចំពោះសំណើសុំមោឃភាព និងចំពោះសំណើសុំផ្អាកនីតិវិធី គឺមានលក្ខណៈដូចគ្នា ជាពិសេសនៅក្នុងករណីដែលសំណើនេះផ្អែកលើអង្គហេតុដូចគ្នា"[6]។

៤. ហេតុដូច្នេះ ការផ្អាកនីតិវិធីអាចអនុញ្ញាតនៅក្នុងករណីមាន (ឬ នឹងមានប្រសិនបើជាការផ្អាកដំណើរការនីតិវិធីមិនត្រូវបានអនុញ្ញាត) កំហុសផ្នែកនីតិវិធី និង"ប្រសិនបើ កំហុសនីតិវិធីធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ភាគីដាក់ពាក្យសុំ"[7]។ អង្គជំនុំជម្រះនេះក៏បានបញ្ជាក់ដែរថា សំណើសុំផ្អាកដំណើរការនីតិវិធី អាចស្ថិត "នៅក្នុងដែនកំណត់ទូទៅនៃពាក្យបណ្តឹងណាមួយ ដែលស្ថិតនៅក្រោមមាត្រា៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលក្នុងនោះចែងពាក់ព័ន្ធពាក់ព័ន្ធថា "ការជំនុំជម្រះត្រូវតែយុត្តិធម៌" ហើយត្រូវប្រព្រឹត្តទៅ "ដោយគោរពយ៉ាងពេញលេញទៅលើសិទ្ធិរបស់ជនជាប់ចោទ..."" [8]។

៥. នៅតុលាការ ICTY យុត្តិសាស្ត្របានបង្កើតឡើងថា នៅពេលដែលជំនុំជម្រះក្តីដោយយុត្តិធម៌មិនអាចធ្វើទៅរួច[9] ការផ្អាកដំណើរការនីតិវិធីអាចត្រូវបានយកមកប្រើ។ អង្គជំនុំជម្រះ មានអំណាចដែលមានជាប់មកជាមួយដើម្បីផ្អាកដំណើរការនីតិវិធី នៅពេលដែលការបន្តនីតិវិធីនឹងរំលោភ

---

[6] *ករណី អៀង ធីរិទ្ធ* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ) "ដីកាបដិសេធសំណើសុំមោឃភាព និងសំណើសុំផ្អាកដំណើការនីតិវិធី ដោយមូលហេតុរំលោភនីតិវិធី ដាក់ដោយ អៀង ធីរិទ្ធ, ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១០ D264/1, ERN: 00422607-00422618 នៅត្រង់កថាខណ្ឌទី ៣០ ។

[7] ដូចខាងលើ យោងសំដៅចំពោះមោឃភាពនៃកិច្ចស៊ើបសួរ ឬ កិច្ចការតុលាការ ។

[8] *ករណី អៀង ធីរិទ្ធ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត បដិសេធសំណើសុំផ្អាកដំណើរនីតិវិធី ដោយមូលហេតុរំលោភនីតិវិធី ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១០ (D264/2/6), ERN: 00543781-00543799 នៅត្រង់កថាខណ្ឌទី ១៣ ។

[9] *សូមមើលរឿងក្តី រដ្ឋអាជ្ញា តទល់ Tadić*, IT-94-1-A សាលដីកា ចុះថ្ងៃទី ១៥ កក្កដា ១៩៩៩ កថាខណ្ឌ ៥៥។

00598666



បំពានសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទ ... [10] ។ "អង្គជំនុំជម្រះសាលាដំបូង ... ពិនិត្យថា តើការបន្តនីតិវិធីអាចធ្វើអោយខូចខាតដល់ដំណើរការដ៏ត្រឹមត្រូវ និងសុច្ចរិតភាពនៃការជំនុំជម្រះក្តីដូចដែលត្រូវបានធានាដោយមាត្រា ២០(១) ... នៃច្បាប់លក្ខន្តិកៈដែរឬទេ"[11]។ ការផ្អាកដំណើរការនីតិវិធី នឹងធ្វើអោយមានសណ្តាប់ធ្នាប់ នៅពេលដែល ឧទាហរណ៍ដូចជា សុច្ចរិតភាពនៃសីលធម៌របស់ដំណើរការនីតិវិធីត្រូវបានទទួលការខូចខាត[12]។

៦. នីតិវិធីត្រូវតែផ្អាក រហូតដល់អង្គបុរេជំនុំជម្រះចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍នេះ។ កសចស បានបញ្ជាក់យ៉ាងច្បាស់ម្តងហើយម្តងទៀតថា កសចស មានបំណងចេញដីកាដំណោះស្រាយនៅក្នុងខែ កញ្ញា[13]។ បើសិនជានីតិវិធី មិនផ្អាកទេនោះ ហើយដីកាដំណោះស្រាយត្រូវបាន

---

[10] *សូមមើលរឿងក្តី រដ្ឋអាជ្ញា តទល់ Bobetko*, IT-02-62-AR54bis សាលដីកាលើការតតាំងដោយប្រទេសក្រូអាត ទៅលើសេចក្តីសម្រេច និងដីកាសម្រេចអះអាងទទួលយកចៅក្រម ចុះថ្ងៃទី ២៩ វិច្ឆិកា ២០០២ កថាខណ្ឌ ១៥។ *សូមមើលផងដែរ សូមមើលរឿងក្តី រដ្ឋអាជ្ញា តទល់ Blagojević*, IT-02-60-AR73.4 សាលដីកាដែលមានសម្អាងហេតុមួយផ្នែកជាសាធារណៈ និងមួយផ្នែកជាសម្ងាត់លើបណ្តឹងឧទ្ធរណ៍របស់ Vidoje Blagojević ដើម្បីដូរផ្លាស់ក្រុមមេធាវីការពារក្តីរបស់ខ្លួន ចុះថ្ងៃទី កថាខណ្ឌ ៧។

[11] *សូមមើលរឿងក្តី រដ្ឋអាជ្ញា តទល់ Prlić et al.*, IT-04-74-T សេចក្តីសម្រេចលើសំណើសុំអោយលើកពេលបណ្តោះអាសន្នដាក់ដោយក្រុមមេធាវីការពារក្តី Praljak Defence ចុះថ្ងៃទី ១៦ មេសា ២០១០ ទំព័រ ៤។

[12] *សូមមើលរឿងក្តី រដ្ឋអាជ្ញា តទល់ Nikolić* IT-94-2-T សេចក្តីសម្រេចលើពាក្យសុំរបស់មេធាវីការពារក្តីតតាំងនឹងការប្រើប្រាស់យុត្តាធិការរបស់អង្គជំនុំជម្រះ ចុះថ្ងៃទី ៩ តុលា ២០០២ កថាខណ្ឌ ៨៩។

[13] កសចស បានប្រកាសកាលពីថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១០ ថា "អាស្រ័យលើការអនុវត្តសិទ្ធិនីតិវិធីរបស់គ្រប់ភាគីទាំងអស់ សហចៅក្រមស៊ើបអង្កេតនឹងព្យាយាមចេញដីកាដំណោះស្រាយនៅត្រឹមខែកញ្ញា ឆ្នាំ២០១០ នេះ" ។ *សូមមើល* សេចក្តីប្រកាសព័ត៌មាន, ការបញ្ចប់កិច្ចស៊ើបសួរនៅក្នុងសំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស អាចរកបាននៅ ttp://www.eccc.gov.kh/english/cabinet/press/141/ECCC_OCIJ_PR14Jan2010-Eng.pdf (បញ្ជាក់បន្ថែម) ។ សហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ ២០១០ បានបញ្ជូនលិខិតមួយច្បាប់ឲ្យសហចៅស៊ើបអង្កេត Marcel Lemonde ដែលមានខ្លឹមសារថា "ខ្ញុំសូមប្រគល់សេចក្តីព្រាងដីកាចាត់ឲ្យស៊ើបសួរជំនួសដែលមានហត្ថលេខារបស់លោក, ហត្ថលេខារបស់ខ្ញុំត្រូវបានឆ្កូតចោល ហើយយើងនឹងពិភាក្សាពីចំណាត់ការនានាទាក់ទងនឹងសំណុំរឿង ០០៣ និង០០៤ នៅខែកញ្ញា ឆ្នាំ២០១០ នៅពេលដែលយើងបញ្ចប់ដីកាដំណោះស្រាយក្នុងសំណុំរឿងលេខ ០០២ ដែលត្រូវបានគេចាត់ទុកថាជាបញ្ហាសំខាន់របស់តុលាការ" ។ *សូមមើល* សេចក្តីប្រកាសព័ត៌មាន សេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០១០ នៅទំព័រ៩ (អត្ថបទបកប្រែក្រៅផ្លូវការ) ។ នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១០ ព្រឹត្តិបត្រសារព័ត៌មានដឹភ្នំពេញប៉ុស្តិ៍ បានស្រង់សំដីមួយផ្នែករបស់អ្នកនាំពាក្យរបស់តុលាការលោក Lars Olsen ដែលបានថ្លែងថា "ឥឡូវនេះវាដល់ដំណាក់កាលចុងក្រោយនៃសំណុំរឿង០០២ ហើយមុននឹងមានសេចក្តីសម្រេចថាតើនឹងមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែរ

ចេញនៅមុនពេលមានសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍នេះ ដីកាដំណោះស្រាយនឹងត្រូវបានគេតាក់តែងដោយមិនអោយ កសចស បានទទួលអត្ថប្រយោជន៍ពីសេចក្តីសន្និដ្ឋាននានាពីមេធាវីការពារក្តីទៅលើផ្នែកច្បាប់ដ៏សំខាន់ៗជាច្រើន។ កសចស នឹងបានទទួលយោបល់ពីតែភាគីម្ខាង ថ្វីបើមានលក្ខខណ្ឌ តម្រូវថា ដំណើរការនីតិវិធីនៅ អវតក ត្រូវមានភាពយុត្តិធម៌ និងចំពោះមុខ[14]។ ដីកាដំណោះស្រាយនឹងសំអាងតែទៅលើសកម្មភាពតុលាការ ដែលរំលោភបំពានសិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបានសមភាពនៃមធ្យោបាយតទល់ក្តី (equality of arms) សិទ្ធិរបស់គាត់ក្នុងការទទួលបានការប្រព្រឹត្តមកលើដោយស្មើភាពគ្នា (equal treatment) និងសិទ្ធិរបស់គាត់ក្នុងការទទួលបាននូវកិច្ចការពារក្តីដែលមានប្រសិទ្ធិភាព ដូច្នេះហើយការជំនុំជម្រះក្តីដោយយុត្តិធម៌នឹងមិនធ្វើទៅបាននោះទេ។

៧. មេធាវីការពារក្តី ដឹងថា បើសិនជា កសចស មិនចេញដីកាដំណោះស្រាយអោយបានមុនថ្ងៃទី ១៩ កញ្ញា ២០១០ ទេនោះ នួន ជា អាចចាំបាច់ត្រូវតែដោះលែងពីការឃុំខ្លួនបណ្តោះអាសន្ន[15]។ ប៉ុន្តែនេះមិនមែនជាមូលហេតុត្រឹមត្រូវក្នុងការបដិសេធមិនព្រមផ្អាកនីតិវិធីឡើយ។ វាមិនមែនដើម្បីប្រយោជន៍យុត្តិធម៌ឡើយដែលផ្តល់ទំងន់ទៅលើការគិតពិចារណាបែបនេះ ឲ្យធ្ងន់ជាងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់លោក អៀង សារី នោះឡើយ។ ធ្វើដូច្នេះ នឹងរំលោភ

---

ឬអត់នោះ" ហើយតុលាការដែលគាំទ្រដោយអង្គការសហប្រជាជាតិ គ្រោងចេញដីកាដំណោះស្រាយនៅក្នុងសំណុំរឿង០០២ នៅត្រឹមខែកញ្ញា<u>ដែលជាកាលបរិច្ឆេទកំណត់ដោយតុលាការ</u>" ។ *សូមមើល* Sebastian Strangio សាលាក្តីខ្មែរក្រហមស្ថិតនៅលើផ្លូវចំពោះការបញ្ជូនសំណុំរឿង ០០២ ទៅជំនុំជម្រះ, ព្រឹត្តិបត្រដឹភ្នំពេញប៉ុស្តិ៍, ចេញផ្សាយនៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១០ (បញ្ជាក់បន្ថែម)។ នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១០ ព្រឹត្តិបត្រសារព័ត៌មានឌឹខេមបូឌា ដេលី និងព្រឹត្តិបត្រសារព័ត៌មានឌឹភ្នំពេញប៉ុស្តិ៍ បានចេញផ្សាយនូវអត្ថបទព័ត៌មានរៀងៗខ្លួនដែលមានខ្លឹមសារថា កសចស នឹងចេញដីកាដំណោះស្រាយនៅខែកញ្ញានេះ ។ ព្រឹត្តិបត្រសារព័ត៌មានឌឹខេមបូឌាដេលី បានស្រង់សំដីលោក Lars Olsen ដែលបានថ្លែងថា "ពួកគេកំពុងតែធ្វើការងារឲ្យទាន់កាលបរិច្ឆេទដើម្បីចេញដីកាដំណោះស្រាយនៅត្រឹម<u>ខែកញ្ញានេះ</u>" ។ *សូមមើល* អត្ថបទសារព័ត៌មានរបស់ Julia Wallace, សហព្រះរាជអាជ្ញាស្វែងរកការបញ្ជូនមេដឹកនាំខ្មែរក្រហមដែលនៅសេសសល់ទៅជំនុំជម្រះ, ព្រឹត្តិបត្រឌឹខេមបូឌាដេលី ចេញផ្សាយនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១០ នៅទំព័រ១ ។ សូមមើលផងដែរអត្ថបទសារព័ត៌មានរបស់ James Otoole "សហព្រះរាជអាជ្ញាដាក់សេចក្តីសន្និដ្ឋានស្ថាពរនៅក្នុងសំណុំរឿង០០២, ព្រឹត្តិបត្រសារព័ត៌មានឌឹភ្នំពេញប៉ុស្តិ៍ ចេញផ្សាយថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១០ នៅទំព័រ ៣ ។

[14] *សូមមើល*វិធាន ២១(១)(ក)។

[15] អនុលោមតាមវិធាន៦៣(៧) នៃវិធានផ្ទៃក្នុង។

00598668



សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដទៃទៀតរបស់លោក អៀង សារី ដូចជាសិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការឯករាជ្យ និងមិនលម្អៀង ជាដើម។ សិទ្ធិនេះ មានន័យថាចៅក្រមដែលពាក់ព័ន្ធក្នុងសំណុំរឿងរបស់លោក អៀង សារី ត្រូវតែធ្វើការសម្រេចចិត្តដោយផ្អែកតែលើអង្គច្បាប់ដែលពាក់ព័ន្ធប៉ុណ្ណោះ។

**គ. សំណើសុំអោយមានសវនាការដេញដោលផ្ទាល់មាត់ជាសាធារណៈ**

៨. បណ្តឹងឧទ្ធរណ៍នេះដោះស្រាយការរំលោភបំពានសិទ្ធិជាមូលដ្ឋានរបស់លោក អៀង សារី ក្នុងទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌។ ការរំលោភបំពាននេះនឹងត្រូវតែទទួលការដោះស្រាយក្នុងរបៀបជាចំហរ និងដោយមានតម្លាភាព។ បញ្ហាដែលមានសារៈសំខាន់បែបនេះត្រូវតែទទួលយកមកកជជែកវែកញែកអោយមានតម្លាភាព ដើម្បីធានាអោយមានផលប្រយោជន៍ដល់សាធារណៈទាំងអស់ ជាពិសេសនៅពេលដែលបញ្ហាទាំងនេះ ទំនងជាជះឥទ្ធិពលដល់ភាពត្រឹមត្រូវស្របច្បាប់ និងភាពជឿជាក់មកលើ អវតក ។

## II. សាវតា

៩. នៅថ្ងៃទី ១៨ កក្កា ២០០៨ កសព បានដាក់ដីកាសន្និដ្ឋានស្ថាពរអនុលោមតាមវិធាន ៦៦ ("ដីកាសន្និដ្ឋានស្ថាពរក្នុងរឿងក្តី ០០១") ទៅ កសចស ។ ដីកាសន្និដ្ឋានស្ថាពរក្នុងរឿងក្តី ០០១ មានកម្រាស់ ៨៦ ទំព័រ [16]។

១០. នៅថ្ងៃទី ២៤ កក្កដា ២០០៨ មេធាវីការពារក្តីលោក កាំង ហ្គេកអ៊ាវ បានដាក់ចម្លើយតបរបស់ខ្លួនតបទៅនឹងដីកាសន្និដ្ឋានស្ថាពរក្នុងរឿងក្តី ០០១ ("ចម្លើយតបក្នុងរឿងក្តី ០០១")។ ចម្លើយតបក្នុងរឿងក្តី ០០១ មានកម្រាស់ ១២ ទំព័រ[17]។

១១. នៅថ្ងៃទី ១៦ សីហា ២០១០ កសព បានដាក់ដីកាសន្និដ្ឋានស្ថាពរក្នុងរឿងក្តី ០០២ ទៅ កសចស។ ដីកាសន្និដ្ឋានស្ថាពរនេះ មានកម្រាស់ ៩៣១ ទំព័រ។

---

[16] *រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ ឌុច* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/កសចស សេចក្តីសន្និដ្ឋានស្ថាពរអនុលោមតាមវិធាន ៦៦ ចុះថ្ងៃទី ១៨ កក្កដា ២០០៨ ឯកសារលេខ D108/55, ERN: 00206175-00206361។

[17] *ករណី កាំង ហ្គេកអ៊ាវ ហៅ ឌុច* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/កសចស សេចក្តីសន្និដ្ឋានរបស់ ឌុច ចុះថ្ងៃទី ២៤ កក្កដា ២០០៨ ឯកសារលេខ D96/1, ERN: 00224323-00224332។

១២. នៅថ្ងៃទី ១៧ សីហា ២០១០ មេធាវីការពារក្តីបានដាក់សំណើជាបន្ទាន់របស់លោក អៀង សារី សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់ដើម្បីដាក់ចម្លើយតបរបស់ខ្លួនទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់ កសព ("សំណើសុំ")[18]។ សំណើសុំបានលើកឡើងថា មេធាវីការពារក្តីមិនអាច "ឆ្លើយតបអោយបានក្បោះក្បាយទៅនឹងដីកាដំណោះស្រាយដែលមានកម្រាស់ ៩៣១ ទំព័រឡើយ។ យោងតាមមាត្រា ៥.៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អវតក កសចស អាចបន្ថែមចំនួនទំព័រកំណត់ ១៥ទំព័រ នៅក្នុងកាលៈទេសៈពិសេស ។ ដោយរក្សានូវកាតព្វកិច្ចខិតខំប្រឹងប្រែងអោយអស់ពីសមត្ថភាព (due diligence ឬ វិរិយភាព) ដែលកំណត់សម្រាប់សហមេធាវី ចម្លើយតបអោយបានក្បោះក្បាយមិនដាក់ជូននៅក្នុងកម្រិតកម្រាស់ទំព័រកំណត់ ១៥ ទំព័រ និងក្នុងរយៈពេលកំណត់ ១៥ថ្ងៃនេះបានឡើយ"[19]។

១៣. នៅថ្ងៃទី ១៩ សីហា ២០១០ កសចស បានច្រានចោលសំណើសុំ ដោយសំអាងថា វា "ហាក់ដូចជាមានការយល់ច្រលំជាថ្មីម្តងទៀត ទាក់ទងទៅនឹងប្រព័ន្ធនីតិវិធីដែលអនុវត្តនៅ អវតក ។ តាមពិតគ្មានបញ្ញត្តិណានៅក្នុងវិធានផ្ទៃក្នុង ចែងអំពីការឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាឡើយ។ បើសិនជាក្នុងករណីរឿងក្តីត្រូវបញ្ជូនទៅជំនុំជម្រះ ទាក់ទងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ មានតែនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងទេ ដែលចរិតលក្ខណៈជជែកតតាំងចំពោះមុខនៃការជំនុំជម្រះដោយយុត្តិធម៌អាចត្រូវយកមកអនុវត្ត ហើយមិនមែននៅមុនពេលចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយសំអាងលើដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាឡើយ ... "[20]។

១៤. នៅថ្ងៃទី ១ កញ្ញា ២០១០ មេធាវីការពារក្តី បានដាក់ចម្លើយតប។ ការដាក់ចម្លើយតបនេះត្រូវបាន

---

[18] *ករណី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស សំណើជាបន្ទាន់របស់លោក អៀង សារី សុំបន្ថែមចំនួនទំព័រ និងពេលវេលាបន្ថែមដើម្បីដាក់ចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់ កសព ចុះថ្ងៃទី ១៧ សីហា ២០១០ ឯកសារលេខ D390/1, ERN: 00593542-00593543 ។

[19] *ដូចយោងខាងលើ* ។

[20] *ករណី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស លិខិតពីសហចៅក្រមស៊ើបអង្កេតមកកាន់មេធាវីការពារក្តី ទាក់ទងនឹងសំណើជាបន្ទាន់របស់ អៀង សារី សុំបន្ថែមចំនួនទំព័រ និងពេលវេលាបន្ថែមដើម្បីដាក់ចម្លើយតបរបស់ខ្លួនទៅនឹងសេចក្តីសន្និដ្ឋានស្ថាពររបស់ កសពស ចុះថ្ងៃទី ១៩ សីហា ២០១០ ឯកសារលេខ D390/1/1, ERN: 00593547-00593547។

ធ្វើឡើងក្នុងរយៈពេលកំណត់ ១៥ថ្ងៃ ប៉ុន្តែមិនស្ថិតនៅក្នុងចំនួនទំព័រកំណត់ ១៥ទំព័រឡើយ។ មេធាវីការពារក្តីបានស្នើថា "កសចស ទទួលយកចម្លើយតបនេះ ថ្វីបើវាឯកចេញពីចំនួនទំព័រកំណត់ក្តី ដើម្បីជាប្រយោជន៍នៃសមភាពនៃមធ្យោបាយតទល់ក្តី"[21]។

១៥. នៅថ្ងៃទី ២ កញ្ញា ២០១០ ចម្លើយតបត្រូវបានបដិសេធដោយ កសចស ដោយសំអាង "ការដាក់ឯកសារមិនគ្រប់គ្រាន់" នៅក្នុងសេចក្តីសម្រេចដែលជំទាស់តវ៉ា។ ក្រឡាបញ្ជី កសចស ក្រោមការណែនាំពី កសចស ជូនដំណឹងដល់មេធាវីការពារក្តីថា៖

សំណើសុំបន្ថែមចំនួនទំព័រកំណត់ត្រូវបានបដិសេធដោយហេតុផលដូចតទៅ៖

- ឯកសារ [sic] មានកម្រាស់ទំព័រច្រើនជាង ៤ដង នៃកម្រាស់ទំព័រដែលបានកំណត់ក្នុងមាត្រា ៥.១ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អវតក ដែលត្រូវបានគោរពដោយការដាក់សារណារបស់មេធាវីនៅក្នុងរឿងក្តី ០០១ ដែលមេធាវីការពារក្តីបានយោងទៅនោះ (D96/1 ចំនួន ១២ទំព័រ)។
- សំណើសុំមិនបានយោងទៅលើកាលៈទេសៈពិសេសណាមួយឡើយ ក្រៅពីតស៊ូមតិណែនាំនូវនីតិវិធីចំពោះមុខ ដូចដែលបានថ្លែងរួចមកហើយនៅក្នុងការបដិសេធពីមុនលើសំណើសុំនេះ (D390/1/1) ដែលមិនមានចែងសម្រាប់ដំណាក់កាលនេះក្នុងនីតិវិធីនៅចំពោះមុខ អវតក ឡើយ[22]។

## III. ច្បាប់ដែលត្រូវយកមកអនុវត្ត

### ក. សិទ្ធិទទួលបានសវនាការដោយយុត្តិធម៌

#### ១. សិទ្ធិទទួលបានសមភាពនៃមធ្យោបាយតទល់ក្តី

១៦. សមភាពនៃមធ្យោបាយតទល់ក្តី គឺជា "គោលការណ៍ច្បាប់ ដែលនៅក្នុងការជំនុំជម្រះក្តីមួយ មេធាវីការពារក្តី និងតំណាងអយ្យការត្រូវតែមានសមភាពខាងនីតិវិធី ដើម្បីធានាថាដំណើរការនៃ

[21] ចម្លើយតប សេចក្តីផ្តើម។

[22] សេចក្តីសម្រេចដែលគេជំទាស់តវ៉ា។

នីតិវិធីតុលាការប្រព្រឹត្តទៅមានយុត្តិធម៌”[23]។ គោលការណ៍នេះគឺជាគោលការណ៍គ្រឹះរបស់បណ្តាលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិនានា រួមមាន កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ (“ICCPR”)[24] ដែលយោងទៅតាមរដ្ឋធម្មនុញ្ញកម្ពុជា ច្បាប់បង្កើត អវតក និង កិច្ចព្រមព្រៀងបង្កើត អវតក ដែល អវតក ត្រូវតែគោរព[25]។ វាក៏មានលក្ខខណ្ឌតម្រូវផងដែរដោយវិធាន ២១(១)(ក) ដែលចែងថា "ដំណើរការនីតិវិធីក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ...។" អង្គជំនុំជម្រះសាលាដំបូងនៅក្នុងរឿងក្តី ០០១ បានអះអាងទទួលយកថា “លក្ខណៈគ្រឹះនៃគោលការណ៍នេះត្រូវបានទទួលស្គាល់នៅក្នុងវិធានផ្ទៃក្នុង...”[26]។ នៅតុលាការ ICTY សិទ្ធិទទួលបានសមភាពនៃមធ្យោបាយតទល់ក្តី ត្រូវបានគេយល់ឃើញថា “ស្ថិតនៅជាបេះដូងនៃការ

---

[23] *រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ ឌុច* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អសជ សេចក្តីសម្រេចលើសំណើសុំរបស់ អៀង សារី ដើម្បីដាក់សារណាជាកិច្ចឆ្លើយតបទៅនឹងសំណើរបស់ សហព្រះរាជអាជ្ញាសុំអោយអនុវត្តសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ៣ កក្កដា ២០០៩ ឯកសារលេខ E90, ERN: 00345178-00345180 កថាខណ្ឌ ៤ ។

[24] ត្រូវបានអនុម័ត និងបើកចំហរអោយមានការចុះហត្ថលេខា ផ្តល់សច្ចាប័ន និងអនុម័តយល់ព្រមដោយសេចក្តីសម្រេចចិត្តលេខ2200A (XXI) របស់មហាសន្និបាទអង្គការសហប្រជាជាតិ ចុះថ្ងៃទី ១៦ ធ្នូ ១៩៦៦ ចូលជាធរមាននៅថ្ងៃទី ២៣ មីនា ១៩៧៦ អនុលោមតាមមាត្រា ៤៩។ យោងតាមមាត្រា (១៤)(១) “ជនគ្រប់រូបត្រូវស្មើភាពគ្នានៅចំពោះមុខតុលាការ និងអង្គជំនុំជម្រះនានា។ នៅក្នុងការសម្រេចអំពីការចោទប្រកាន់ពីបទព្រហ្មទណ្ឌប្រឆាំងមកលើខ្លួន ឬអំពីសិទ្ធិនិងករណីកិច្ច នៅក្នុងបណ្តឹងមួយ បុគ្គលម្នាក់ៗត្រូវមានសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងជាសាធារណៈ ដោយតុលាការមានសមត្ថភាព ឯករាជ្យ និងឥតលំអៀង ... ។” *សូមមើលផងដែរ* រឿងក្តី *Fei តទល់នឹងប្រទេស Colombia* បណ្តឹងលេខ514/1992, U.N. Doc. CCPR/C/53/D/514/1992 (1995) កថាខណ្ឌ ៨.៤ ចែងថា “ទស្សនៃ “ការជំនុំជម្រះក្តីយុត្តិធម៌” នៅក្នុងអត្ថន័យនៃមាត្រា១៤ កថាខណ្ឌ ១ ... ក៏រួមបញ្ចូលនូវធាតុផ្សេងទៀតផងដែរ។ ក្នុងចំណោមធាតុទាំងនោះ គណៈកម្មាធិការបានមានឱកាសដើម្បីចង្អុលប្រាប់ ... គឺការគោរពគោលការណ៍សមភាពនៃមធ្យោបាយតទល់ក្តី គោលការណ៍នៃនីតិវិធីចំពោះមុខ និងគោលការណ៍នៃនីតិវិធីឆាប់រហ័ស ...”។

[25] *សូមមើល* រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ ១៩៩៣ ដែលបានធ្វើវិសោធនកម្មក្នុងឆ្នាំ ១៩៩៩ មាត្រា ៣១។ មាត្រានេះចែងតម្រូវថា តុលាការកម្ពុជា “ទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ”។

[26] *រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ ឌុច* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អសជ សេចក្តីសម្រេចលើសំណើសុំរបស់ អៀង សារី ដើម្បីដាក់សារណាជាកិច្ចឆ្លើយតបទៅនឹងសំណើរបស់ សហព្រះរាជអាជ្ញាសុំអោយអនុវត្តសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ៣ កក្កដា ២០០៩ ឯកសារលេខ E90, ERN: 00345178-00345180 កថាខណ្ឌ ៤ ។។

00598672



ធានាអោយជំនុំជម្រះក្តីមានយុត្តិធម៌"[27]។

## ២. សិទ្ធិទទួលបានការប្រព្រឹត្តមកលើដោយស្មើគ្នានៅចំពោះមុខច្បាប់

១៧. សិទ្ធិទទួលបានការប្រព្រឹត្តមកលើដោយស្មើគ្នានៅចំពោះមុខច្បាប់ ត្រូវបានធានាដោយរដ្ឋធម្មនុញ្ញកម្ពុជា ក៏ដូចជានីតិវិធីព្រហ្មទណ្ឌកម្ពុជា និងលិខិតុបករណ៍អន្តរជាតិមួយចំនួនទៀត។ មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជាចែងថា "ពលរដ្ឋខ្មែរគ្រប់រូប មានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ..." ។

១៨. មាត្រា ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ចែងថា "បណ្តឹងអាជ្ញាអនុវត្តទៅលើបុគ្គលគ្រប់រូប ទាំងរូបវន្តបុគ្គល ទាំងនីតិបុគ្គល ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើម្បីកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ"[28]។

១៩. មាត្រា ៧ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ("UDHR") ចែងថា "ទាំងអស់គ្នាគឺស្មើភាពគ្នានៅចំពោះមុខច្បាប់ និងមានសិទ្ធិទទួលបានកិច្ចការពារស្មើភាពគ្នាដោយគ្មានការរើសអើង"។ ទាំងអស់គ្នាមានសិទ្ធិទទួលបានការការពារស្មើភាពគ្នាប្រឆាំងនឹង ការរំលោភបំពានលើសេចក្តីប្រកាសនេះ និងប្រឆាំងនឹងការញុះញង់អុចអាលអោយមានការរើសអើងបែបនេះ[29]។

២០. មាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ("ICCPR") បានចែងថាៈ "ជនគ្រប់រូបត្រូវស្មើភាពគ្នានៅចំពោះមុខតុលាការ និងអង្គជំនុំជម្រះនានា។ ហើយមាត្រា ២៦ ចែងថា "ជនគ្រប់រូបមានត្រូវស្មើភាពគ្នានៅចំពោះមុខច្បាប់ និងមានសិទ្ធិទទួលបានការ

---

[27] *សូមមើលរឿងក្តី រដ្ឋអាជ្ញា តទល់ Tadić*, IT-94-1-A សាលដីកា ចុះថ្ងៃទី ១៥ កក្កដា ១៩៩៩ កថាខណ្ឌ ៤៤។ *សូមមើលផងដែរ សូមមើលរឿងក្តី រដ្ឋអាជ្ញា តទល់ Delalić et al.*, IT-96-21-T សេចក្តីសម្រេចលើពាក្យសុំរបស់ អយ្យការសុំអោយចេញដីកាបង្គាប់អោយមេធាវីការពារក្តីលាតត្រដាងជាមុននូវសាក្សីមួយចំនួន ចុះថ្ងៃទី ៤ កុម្ភៈ ១៩៩៨ កថាខណ្ឌ ៤៥ នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា សមភាពនៃមធ្យោបាយការពារក្តី "គឺជាលក្ខណៈវិនិច្ឆ័យដ៏សំខាន់បំផុតនៃសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌។ គោលការណ៍នេះតម្រូវអោយមានការរក្សានូវតុល្យភាពនៃយុត្តិធម៌រវាងគូភាគី ហើយអនុវត្តទៅលើទាំងរឿងក្តីរដ្ឋប្បវេណី និងរឿងក្តីព្រហ្មទណ្ឌ" ។

[28] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៨។

[29] សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស G.A. Res. 217A(III), U.N. GAOR, 3d Sess. at 71, U.N. Doc. A/810 (1948)។

00598673



ការពារដោយច្បាប់ដោយឥតរើសអើង"។

## ៣. សិទ្ធិក្នុងការត្រៀមរៀបចំកិច្ចការពារក្តីអោយបានពេញលេញ

២១. មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជាចែងថា "ពលរដ្ឋគ្រប់រូបមានសិទ្ធិទទួលបានការការពារតាមផ្លូវតុលាការ"

២២. មាត្រា ១៣(១) នៃកិច្ចព្រមព្រៀង ចែងថា៖

> សិទ្ធិរបស់ជនជាប់ចោទ ដែលមានចែងនៅក្នុងមាត្រា ១៤ និង១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវតែបានគោរពនៅទូទាំងដំណើរការនៃការជំនុំជម្រះក្តី។ សិទ្ធិបែបនេះជាពិសេសរួមមានសិទ្ធិទទួលបាននូវសវនាការមួយត្រឹមត្រូវ និងជាសាធារណៈ សិទ្ធិត្រូវបានចាត់ទុកថាគ្មានទោសពៃរ៍ រហូតដល់ពេលរកឃើញថាជាប់ពិរុទ្ធ សិទ្ធិជ្រើសរើសមេធាវីដោយខ្លួនឯង <u>សិទ្ធិមានពេលវេលា និង លក្ខណៈគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំការពារខ្លួន</u> ...[30]។

២៣. មាត្រា ៣៥ ថ្មី នៃច្បាប់ស្តីពីបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចែងថា:

> នៅក្នុងការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមា និងស្មើគ្នាសមស្របតាមមាត្រា ១៤ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ... ខ. <u>មានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ ដើម្បីរៀបចំការពារខ្លួន និងទាក់ទងជាមួយមេធាវីរបស់ ខ្លួនដែលជ្រើសរើសដោយខ្លួនឯង</u>...[31]។

២៤. មាត្រា ១៤(៣) នៃ ICCPR ចែងថា

> នៅក្នុងការចោទប្រកាន់ពីបទព្រហ្មទណ្ឌមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបាននូវការធានាជាអប្បរមា និងស្មើគ្នា៖ ... (ខ) <u>មានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារខ្លួន</u> ... [32]។

---

[30] គូសបញ្ជាក់បន្ថែម។

[31] គូសបញ្ជាក់បន្ថែម។

[32] គូសបញ្ជាក់បន្ថែម។

00598674



២៥. មាត្រា ១១(១) នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ("UDHR") ចែងថា "ជនណាដែលជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ ត្រូវសន្មតជាជនគ្មានទោស រហូតដល់ពិរុទ្ធភាពត្រូវបានរកឃើញថាមានទោសតាមច្បាប់នៅក្នុងសវនាការជាសាធារណៈ ដែលមានការធានាចាំបាច់សម្រាប់កិច្ចការពារក្តីរបស់ជនជាប់ចោទ"[33]។

**ខ. សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អវតក ("សេចក្តីណែនាំអនុវត្តដាក់ឯកសារ")**

២៦. មាត្រា ៥(១) នៃសេចក្តីណែនាំអនុវត្តដាក់ឯកសារ ចែងថា "ឯកសារដាក់នៅសហចៅក្រមស៊ើបអង្កេត ឬ នៅអង្គជំនុំជម្រះសាលាដំបូង មិនត្រូវលើសពី ១៥ទំព័រជាភាសាអង់គ្លេស ឬបារាំង ឬ ៣០ទំព័រជាភាសាខ្មែរ លើកលែងតែមានបញ្ញត្តិចែងផ្ទុយពីនេះ នៅក្នុងវិធានផ្ទៃក្នុងនៃ អវតក ឬ សេចក្តីណែនាំអនុវត្តនេះ ឬ បទបញ្ជាចេញដោយ អវតក"។

២៧. មាត្រា ៥(៤) នៃសេចក្តីណែនាំអនុវត្តដាក់ឯកសារ ចែងថា "តាមការស្នើសុំរបស់ភាគីចូលរួមសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ ដែលពាក់ព័ន្ធ អាចបង្កើនចំនួនសន្លឹករបស់ឯកសារនៅក្នុងកាលៈទេសៈពិសេស"។

២៨. មាត្រា ៥(៥)(គ) នៃសេចក្តីណែនាំអនុវត្តដាក់ឯកសារ ចែងថា "ចំពោះឯកសារដូចខាងក្រោម ពុំមានកំណត់ចំនួនសន្លឹកទេ៖ ... គ. ដីកាសន្និដ្ឋានស្ថាពរ (វិធាន ៦៦ នៃវិធានផ្ទៃក្នុង"។

២៩. មាត្រា ១០(១) នៃសេចក្តីណែនាំអនុវត្តដាក់ឯកសារ ចែងថា "ក្រឡាបញ្ជីដែលពាក់ព័ន្ធ ត្រូវទទួលខុសត្រូវក្នុងការពិនិត្យផ្ទៀងផ្ទាត់អំពីទំរង់បែបបទនៃ ឯកសារដែលបានដាក់ ឲ្យបានស្របទៅតាមបទប្បញ្ញត្តិដូចមានចែងក្នុងសេចក្តីណែនាំអនុវត្តនេះ"។

## IV. អំណះអំណាង

**ក. សេចក្តីសម្រេចដែលគេជំទាស់តវ៉ារំលោភបំពានសិទ្ធិលោក អៀង សារី ក្នុងការទទួលបានសមភាពនៃមធ្យោបាយការពារក្តី**

៣០. សេចក្តីសម្រេចដែលគេជំទាស់តវ៉ា រំលោភបំពានសិទ្ធិលោក អៀង សារី ក្នុងការទទួលបាន

---

[33] គូសបញ្ជាក់បន្ថែម។

សមភាពនៃមធ្យោបាយការពារក្តី ដែលជាសិទ្ធិមួយនៃសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌។ សេចក្តីណែនាំអនុវត្តដាក់ឯកសារ អនុញ្ញាតអោយ កសព ដាក់ដីកាសន្និដ្ឋានស្ថាពរដោយគ្មានកំណត់ចំនួនទំព័រអ្វីទាំងអស់[34]។ ដីកាសន្និដ្ឋានស្ថាពរ គឺមានន័យថា ជាការដាក់ឯកសារ "សុំទៅសហចៅក្រមស៊ើបអង្កេតឲ្យធ្វើដីកាដំណោះស្រាយ ចំពោះសំណុំរឿងណាមួយ[35]" ដែលគួរ "សុំឲ្យសហចៅក្រមស៊ើបអង្កេតធ្វើការចោទប្រកាន់ និង បញ្ជូនជនត្រូវចោទនេះទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់"[36]។

៣១. គ្មានវិធានណាមួយនៅក្នុងវិធានផ្ទៃក្នុង ចែងថា ដីកាសន្និដ្ឋានស្ថាពរត្រូវកំណត់ពីអ្វីដែល កសព ជឿថាជាច្បាប់ដែលអាចយកមកអនុវត្តនៅ អវតកត នោះទេ។ ប៉ុន្តែ ក្រោយពីពេលដែល កសព ធ្វើដូច្នេះ មេធាវីការពារក្តី ដាច់ខាតត្រូវតែមានសិទ្ធិដើម្បីឆ្លើយតប។ គ្មានវិធានណាមួយនៅក្នុងវិធានផ្ទៃក្នុងហាមឃាត់មេធាវីការពារក្តី មិនអោយឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ[37]ឡើយ

---

[34] សេចក្តីណែនាំអនុវត្តដាក់ឯកសារ មាត្រា ៥.៥។

[35] វិធានផ្ទៃក្នុង សន្ទានុក្រម។

[36] វិធាន ៦៦(៥)។

[37] ថ្វីបើចំណុចនេះទំនងជាដូចអ្វីដែល កសចស បានលើកឡើងក៏ដោយ។ សេចក្តីសម្រេចដែលគេជំទាស់តវ៉ា បានថ្លែងថា សំណើសុំ "ក្រៅពីគស្ទីមតិណែនាំនូវនីតិវិធីចំពោះមុខ ... ដែលមិនមានចែងសម្រាប់ដំណាក់កាលនេះក្នុងនីតិវិធី" ហើយលិខិតដែលបដិសេធចំពោះសំណើរបស់មេធាវីការពារក្តី សុំអោយមានការបន្ថែមចំនួនទំព័រ និងពេលកំណត់ ដោយថ្លែងថា "គ្មានវិធានណាមួយនៅក្នុងវិធានផ្ទៃក្នុងហាមឃាត់មេធាវីការពារក្តី មិនអោយឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ" ។ *សូមមើល ករណី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស លិខិតពីសហចៅក្រមស៊ើបអង្កេតមកកាន់មេធាវីការពារក្តី ទាក់ទងនឹងសំណើជាបន្ទាន់របស់ អៀង សារី សុំបន្ថែមចំនួនទំព័រ និងពេលវេលាបន្ថែមដើម្បីដាក់ចម្លើយតបរបស់ខ្លួនទៅនឹងសេចក្តីសន្និដ្ឋានស្ថាពររបស់ កសពស ចុះថ្ងៃទី ១៩ សីហា ២០១០ ឯកសារលេខ D390/1/1, ERN: 00593547-00593547។ វិធាន ២១ ផ្តល់អំណាចយ៉ាងច្បាស់លាស់ថា "ដំណើរការនីតិវិធីក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌និងត្រូវគោរពគោលការណ៍ចំពោះមុខ" ។ កសចស បានយល់ឃើញដោយមិនត្រឹមត្រូវនៅក្នុងសេចក្តីសម្រេចដែលគេជំទាស់តវ៉ា ថា "នីតិវិធីចំពោះមុខ ... មិនមានចែងសម្រាប់ដំណាក់កាលនេះក្នុងនីតិវិធីនៅចំពោះមុខ អវតក ឡើយ" ។ ដំណើរការនីតិវិធីក្នុងអង្គជំនុំជម្រះវិសាមញ្ញ គឺមានលក្ខណៈចំពោះមុខនៅក្នុងដំណាក់កាលនេះ ដោយវាបានបញ្ជាក់យ៉ាងច្បាស់លាស់នៅក្នុងសំណុំរឿង ០០១ តាមរយៈសេចក្តីសម្រេចទទួលយកការដាក់ចម្លើយតបរបស់ កាំង ហ្កេកអ៊ាវ ទៅនឹងដីកាសន្និដ្ឋានស្ថាពរនៅក្នុងសំណុំរឿង ០០១។

ហើយគូភាគី ជាធម្មតា ត្រូវបានអនុញ្ញាតអោយឆ្លើយតបទៅនឹងបញ្ហានានាមួយចំនួន[38]។ មេធាវីការពារក្តី ស្នើសុំអោយមានចំនួនទំព័រកំណត់ដើម្បីឆ្លើយតប មិនមែនដូចដែល កសចស បាន អះអាង ដោយសំអាងលើ "ការយល់ច្រលំជាថ្មីម្តងទៀត ទាក់ទងទៅនឹងប្រព័ន្ធនីតិវិធីដែលអនុវត្តនៅ អវតក"[39] នោះទេ។ វាសំអាងលើសិទ្ធិជាមូលដ្ឋានរបស់លោក អៀង សារី ក្នុងការទទួលបានសមភាពនៃមធ្យោបាយការពារក្តី។ "វាបានត្រឹមតែថាគេមិនបានធ្វើអោយយុត្តិធម៌ឡើយ ដោយផ្តល់អោយគូប្រកួតប្រជែងម្ខាង នៅក្នុងសង្គ្រាមនាពេលកាត់ក្តី នូវលំពែង និងខែល ហើយប្រគល់អោយភាគីម្ខាងទៀតត្រឹមតែកូនកាំបិតមួយនោះ ។ សមភាពនៃមធ្យោបាយការពារក្តី គឺមានលក្ខណៈជាសារវ័ន្តដល់ការស្វែងរកភាពយុត្តិធម៌ និងការពិត"[40]។

គោលការណ៍សមភាពនៃមធ្យោបាយការពារក្តី មិនមែនគ្រាន់តែផ្តល់ឱកាសអោយមានការចូលរួមស្មើភាពគ្នាដល់គូភាគីនោះ ទេ ប៉ុន្តែវាក៏ជួយពង្រឹងសុក្រិតភាព ដោយធានាថាប្រភពព័ត៌មាន ដែលបានទាញអារម្មណ៍របស់តុលាការ មិនត្រូវបានពង្វាងហួសហេតុដោយភាគី

---

[38] *សូមមើលជាឧទាហរណ៍ ករណី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស(អបជ៥៦) សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញាទៅលើបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីស្តីពី ការព្រមានរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ៩ មេសា ២០១០ ឯកសារលេខ D367/1/2, ERN 00495289-00495291 ។ *ករណី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ២៥) ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, នួន ជា, ខៀវ សំផន និង អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលបដិសេធសំណើរួមរបស់មេធាវីការពារក្តី សុំអោយបំពេញកិច្ចស៊ើបសួរ ដើម្បីស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួមក្នុងកុំព្យូទ័រ ចុះថ្ងៃទី ១០ សីហា ២០០៩ ឯកសារលេខ D164/3/2, ERN:00360910-00360929 ។*ករណី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស(អបជ៦៤) សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ស្តីពីការថតសម្លេង និងរូបភាពនៅមន្ទីរឃុំឃាំង ("ចម្លើយតបរបស់ កសព") ចុះថ្ងៃទី ៦ ឧសភា ២០១០ ឯកសារលេខ A371/2/2, ERN: 00511628-00511631។

[39] *ករណី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស លិខិតពីសហចៅក្រមស៊ើបអង្កេតមកកាន់មេធាវីការពារក្តី ទាក់ទងនឹងសំណើជាបន្ទាន់របស់ អៀង សារី សុំបន្ថែមចំនួនទំព័រ និងពេលវេលាបន្ថែមដើម្បីដាក់ចម្លើយតបរបស់ខ្លួនទៅនឹងសេចក្តីសន្និដ្ឋានស្ថាពររបស់ កសពស ចុះថ្ងៃទី ១៩ សីហា ២០១០ ឯកសារលេខ D390/1/1, ERN: 00593547-00593547។

[40] អត្ថបទរបស់ Jay Sterling Silver ក្រោមចំណងជើងថា *សមភាពនៃមធ្យោបាយការពារក្តី និងដំណើរការនីតិវិធីចំពោះមុខដឹកនាំដោយភាគី៖ សិទ្ធិតាមរដ្ឋធម្មនុញ្ញថ្មី* (*Equality of Arms and the Adversarial Process: A New Constitutional Right)*, 1990 WIS. L. REV. 1007, 1037 (1990).

តែម្ខាង ... ។ <u>គោលការណ៍ទាំងនេះមិនតម្រូវថា ច្បាប់នីតិវិធីខំម៉ុនឡ (common law) ត្រូវបានគេអនុម័តយកទាំងស្រុងនោះទេ៖</u> វាត្រឹមតែថាគោលការណ៍ទាំងនេះផ្តល់ជាមធ្យោបាយដើម្បីដើរអោយហួសពីដែនកំណត់នៃ ប្រពៃណីនៃនីតិវិធីចំពោះមុខដឹកនាំដោយភាគី (adversarial) និងនីតិវិធីដឹកនាំជជីកសួរហេតុផលដោយចៅក្រម (inquisitorial) ហើយប្រែមកជាពឹងពាក់គ្នាច្រើន ... នៅក្នុងករណីនៃនីតិវិធីជជីកសួរហេតុផលដោយចៅក្រម (inquisitorial)របស់ប្រព័ន្ធស៊ីវិលឡ (civil law) ទៅលើកង្វះខាតនៃចៅក្រមជំនុំជម្រះ ឬចៅក្រមស៊ើបសួរ[41]។

៣២. សេចក្តីសម្រេចដែលគេជំទាស់តវ៉ា ថ្លែងថា សំណើសុំ "មិនយោងទៅលើកាលៈទេសៈពិសេសណាមួយ" ដូចដែលតម្រូវអោយមានសម្រាប់ការបន្ថែមចំនួនទំព័រកំណត់អនុលោមទៅតាមមាត្រា ៥.៤ នៃសេចក្តីណែនាំអនុវត្តដាក់ឯកសារ ។ តាមពិត សំណើសុំពិតជាបាននិយាយយោងទៅលើកាលៈទេសៈពិសេស។ សំណើសុំបានថ្លែងថា មេធាវីការពារក្តីមិនអាច "ឆ្លើយតបអោយបានក្បោះក្បាយទៅនឹងដីកាសន្និដ្ឋានស្ថាពរដែលមានកម្រាស់ ៩៣១ទំព័រ ត្រឹមកម្រិត ១៥ទំព័របានឡើយ"[42]។ សំណើសុំនេះក៏បានយោងយ៉ាងជាក់លាក់ទៅលើឆន្ទានុសិទ្ធិរបស់ កសចស ក្នុងបន្ថែមចំនួនទំព័រកំណត់នៅក្នុងកាលៈទេសៈពិសេស ។ នៅក្នុងបរិបទនេះ ដីកាសន្និដ្ឋានស្ថាពរដែលមានកម្រាស់ ៩៣១ទំព័រ ជាក់ស្តែងបង្កើតបានជាកាលៈទេសៈពិសេសដើម្បីធ្វើយុត្តិកម្មចំពោះការបន្ថែមចំនួនទំព័រកំណត់សម្រាប់ចម្លើយតប។ ការយល់ឃើញផ្សេងពីនេះ ដូចដែល កសចស បានធ្វើ គឺផ្តល់អាទិភាពខ្ពស់ដល់លក្ខខណ្ឌតម្រូវខាងទម្រង់ការជាជាងលើខ្លឹមសារនៃសិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌។ វិធីសាស្ត្របែបនេះគឺមិនសមរម្យនៅក្នុងករណីដែលបែបនេះឡើយ នៅពេលដែលសិទ្ធិមនុស្សដ៏សំខាន់ដូចជាសិទ្ធិក្នុងការទទួលបានសមភាពនៃមធ្យោបាយការពារក្តីនេះជាដើម កំពុងស្ថិតក្នុងហានិភ័យ[43]។

---

[41] អត្ថបទរបស់ John Jackson, ក្រោមចំណងជើងថា *Finding the Best Epistemic Fit for International Criminal Tribunals; Beyond the Adversarial-Inquisitorial Dichotomy*, 7(1) J. INT"L CRIM. JUST. 17, 23-24 (2009) (គូសបញ្ជាក់បន្ថែម) ។

[42] គូសបញ្ជាក់បន្ថែម ។

[43] *សូមមើល* តុលាការពិសេសសម្រាប់ Lebanon ដីកាសម្រេចប្រគល់បញ្ហាទៅចៅក្រមអង្គបុរេជំនុំជម្រះ CH/PRES/2010/01 ចុះថ្ងៃទី ១៥ មេសា ២០១០ កថាខណ្ឌ ១៦។ នៅក្នុងដីកាសម្រេចនេះ ចៅក្រម Cassesse យល់ឃើញថា វិធាននៃទម្រង់

00598678



៣៣. ដោយពិចារណាទៅលើដីកាសន្និដ្ឋានស្ថាពរ ដែលមាន ៩៣១ទំព័រ ការអនុញ្ញាតអោយដាក់ចម្លើយតប[44]ដែលមាន ៦៦ទំព័រ នឹងបានឃើញត្រឹមកម្រិតអប្បបរិមាដែល កសចស អាចបានធ្វើដើម្បីបំពេញនូវលក្ខខណ្ឌជាមូលដ្ឋាននេះ។ ចម្លើយតបមិនមែនវែងពេកដោយគ្មានសមាមាត្រនោះទេ ហើយការដាក់ចម្លើយតបនេះ នឹងមិនមានផលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការឆាប់រហ័សនៃរឿងក្តីដែលប្រឆាំងនឹងលោក អៀង សារី ឡើយ។

៣៤. តុលាការសិទ្ធិមនុស្សអឺរ៉ុបបានយល់ឃើញថា សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌បានទទួលការរំលោភបំពាននៅពេល ដែលអ្នកប្តឹង (applicant) ត្រូវបានគេបដិសេធនូវឱកាសដើម្បីឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ដែលបានដាក់ដោយមេធាវីតំណាងអោយរដ្ឋ (state counsel)[45]។ នៅក្នុងរឿងក្តី *Ruiz-Mateos តទល់នឹងប្រទេសអេស្ប៉ាញ (Spain)* អ្នកប្តឹងចោទប្រកាន់ពីការរំលោភបំពាន គោលការណ៍សមភាពនៃមធ្យោបាយការពារក្តី ដោយឈរលើមូលដ្ឋានថា មេធាវីតំណាងអោយរដ្ឋនៅក្នុងដំណើរការនីតិវិធីរដ្ឋប្បវេណី មានលទ្ធភាពដាក់ជូនតុលាការធម្មនុញ្ញ នូវសេចក្តីសង្កេតជាលាយលក្ខណ៍អក្សរស្តីពីភាពស្របច្បាប់របស់ច្បាប់មួយ (statute) ខណៈដែលអ្នកប្តឹងមិនត្រូវបានអនុញ្ញាតអោយធ្វើដូច្នេះដោយសារតែពួកគេត្រូវបានគេ

---

អាចមិនទាក់ទងនៅក្នុង "កិច្ចដំណើការនីតិវិធី*ព្រហ្មទណ្ឌ*អន្តរជាតិ គិតត្រឹមកម្រិតដែលថាពាក្យសុំបែបនេះ (១) មិនត្រូវបានធ្វើឡើងដើម្បីធ្វើអោយខូចខាតដល់សិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទ ជនរងគ្រោះ ឬ សាក្សី ឬបុគ្គលនានាដទៃទៀត ដែលមានមុខនៅចំពោះតុលាការព្រហ្មទណ្ឌអន្តរជាតិនានា និង (២) មិនបង្កបានការរំលោភបំពានធ្ងន់ធ្ងរដល់បញ្ញត្តិនីតិវិធីតឹងរឹងដែលមានគោលដៅការពារដល់គោលការណ៍យុត្តិធម៌ដែលត្រឹមត្រូវ និងមានភាពឆាប់រហ័ស"។

[44] សិទ្ធិក្នុងការការទទួលបានសមភាពនៃមធ្យោបាយតទល់ក្តីដែលជាសិទ្ធិជាមូលដ្ឋាននៃការជំនុំជម្រះក្តីដោយយុត្តិធម៌របស់លោក អៀង សារី ពន្យល់ថា ហេតុអ្វីបានជាគាត់បានប្រើជម្រើសដាក់បណ្តឹងឧទ្ធរណ៍នេះ ដែលផ្ទុយពីការឡើងវិញនូវចម្លើយតបដែលបង្រួមខ្លីត្រឹម ១៥ ទំព័រ ទៅ កសចស ដូចដែលបានអនុញ្ញាតតាមមាត្រា ១០(២) នៃសេចក្តីណែនាំអនុវត្តដាក់ឯកសារ។ នៅក្នុងកាលៈទេសៈទាំងនេះ វានឹងរំលោភបំពានសិទ្ធិក្នុងការការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់លោក អៀង សារី ដោយត្រូវបង្រួមការដាក់ឯកសារមកត្រឹម ១៥ទំព័រ ដោយពិចារណាពីបញ្ហាអង្គច្បាប់សំខាន់ៗមួយចំនួន ដែលត្រូវតែបានគេដោះស្រាយជាកិច្ចឆ្លើយតបទៅនឹងការដាក់ដីកាសន្និដ្ឋានស្ថាពរ។ លើសពីនេះ មាត្រា ៩ នៃសេចក្តីណែនាំអនុវត្តដាក់ឯកសារ ផ្តល់អោយ កសចស នូវឆន្ទានុសិទ្ធិក្នុងការច្រានចោលការដាក់ឯកសារឡើងវិញ ។ ដោយសារភាពមិនសមហេតុផល និងតាមទំនើងចិត្តនៃវិធីសាស្ត្ររបស់ កសចស ទៅលើបញ្ហាមួយពីមុនមក មេធាវីការពារក្តីពិចារណាអំពីអ្វីដែលជាដំណើរការដែលឆាប់រហ័យបំផុតគឺការដាក់បណ្តឹងឧទ្ធរណ៍នេះទៅអង្គបុរេជំនុំជម្រះ។

[45] *សូមមើលរឿងក្តី Ruiz-Mateos តទល់នឹងប្រទេសអេស្ប៉ាញ* របស់តុលាការសិទ្ធិមនុស្សអឺរ៉ុប Eur. Ct. H.R., 16 E.H.R.R. 505 សាលក្រម ចុះថ្ងៃទី ២៣ មិថុនា ១៩៩៣ Application No. 12952/87 កថាខណ្ឌ ៦៣-៦៨។

យល់ឃើញថាខ្វះលក្ខណៈជាភាគី (locus standi) [46]។ តុលាការបានយល់ឃើញថា "ក្នុងលក្ខណៈជាវិធានច្បាប់ បុគ្គលនានាត្រូវតែទទួលបានការធានាអោយមានការទទួលបាននូវសេចក្ដីសង្កេតការណ៍នានា (observations) របស់ភាគីដទៃទៀតនៅក្នុងដំណើរការនីតិវិធីទាំងនេះ ហើយមានឱកាសពិតប្រាកដ (genuine opportunity) ដើម្បីមានមតិយោបល់ទៅលើសេចក្ដីសង្កេតការណ៍ទាំងនោះ"[47]។ ករណីនេះគឺមានលក្ខណៈប្រដូចប្រសងគ្នាទៅនឹងស្ថានភាព ដែលលោក អៀង សារី បានជួបប្រទះ ដោយហេតុថា លោក អៀង សារី ត្រូវបានគេរាំងមិនអោយមានឱកាសពិតប្រាកដ ដើម្បីមានមតិយោបល់ទៅលើដីកាសន្និដ្ឋានស្ថាពររបស់ កសព ។ ឱកាសដើម្បីមានមតិយោបល់ត្រឹម ១៥ទំព័រ ទៅលើដីកាសន្និដ្ឋានស្ថាពរដែលមានកម្រាស់ ៩៣១ទំព័រ គឺមិនមែនជាឱកាសពិតប្រាកដនោះទេ។

**ខ. សេចក្ដីសម្រេចដែលគេជំទាស់តវ៉ារំលោភបំពានសិទ្ធិលោក អៀង សារី ក្នុងការទទួលបានការប្រព្រឹត្តមកលើដោយស្មើភាពគ្នាចំពោះមុខច្បាប់**

៣៥. លោក អៀង សារី មានសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការប្រព្រឹត្តមកលើដោយស្មើភាពគ្នានៅចំពោះមុខច្បាប់។ សិទ្ធិនេះគឺត្រូវបានធានាជូនគាត់តាមរយៈមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា និងក្រោមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[48]។ សិទ្ធិនេះក៏មានចែងនៅក្នុង UDHR[49] និង ICCPR[50] ផងដែរ ដែល អវតក ត្រូវតែគោរពអនុលោមទៅតាមរដ្ឋធម្មនុញ្ញកម្ពុជា[51]។

៣៦. សេចក្ដីសម្រេចដែលគេជំទាស់តវ៉ា រំលោភលើសិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបានការប្រព្រឹត្តមកលើដោយស្មើភាពគ្នានៅចំពោះមុខច្បាប់ ដោយសារតែសេចក្ដីសម្រេចដែលគេជំទាស់តវ៉ានេះប្រព្រឹត្តមកលើលោក អៀង សារី ខុសគ្នាពីលោក កាំង ហ្គេកអ៊ាវ ដែលត្រូវបានអនុញ្ញាត

---

[46] *ដូចយោងខាងលើ* កថាខណ្ឌ ៦១។

[47] *ដូចយោងខាងលើ* ។ (គូសបញ្ជាក់បន្ថែម) កថាខណ្ឌ ៦៣ ។

[48] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ៣។

[49] មាត្រា ៧ នៃ UDHR ។

[50] មាត្រា ១៤(១) និង មាត្រា ២៦ នៃ ICCPR ។ មាត្រា ២៦ ចែងថា "ជនគ្រប់រូបមានត្រូវស្មើភាពគ្នានៅចំពោះមុខច្បាប់ និងមានសិទ្ធិទទួលបានការការពារដោយច្បាប់ដោយឥតរើសអើង"។

[51] រដ្ឋធម្មនុញ្ញកម្ពុជា មាត្រា ៣១។ អវតក ត្រូវតែគោរពផងដែរនូវសិទ្ធិនានាដែលមានចែងនៅក្នុង ICCPR ដោយអនុលោមទៅតាមមាត្រា ១៣ នៃកិច្ចព្រមព្រៀង និងមាត្រា ៣៥ថ្មី នៃច្បាប់បង្កើត អវតក។

អោយឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរនៅក្នុងនៅក្នុងសំណុំរឿង ០០១ ។ កសចស ពន្យល់ថា ការប្រព្រឹត្តមកលើខុសគ្នានេះ ដោយសំអាងមកពីហេតុដែលចម្លើយតបរបស់លោក កាំង ហ្គេក អ៊ាវ ទៅនឹងដីកាសន្និដ្ឋានស្ថាពរនៅក្នុងនៅក្នុងសំណុំរឿង ០០១ គឺធ្វើក្នុងរង្វង់ ១៥ទំព័រកំណត់សម្រាប់ការដាក់ឯកសារនៅចំពោះមុខ កសចស[52]។ ប៉ុន្តែ សូមធ្វើការគូសបញ្ជាក់ថា ដីកាសន្និដ្ឋានស្ថាពរនៅក្នុងនៅក្នុងសំណុំរឿង ០០១ គឺមានកម្រាស់តែ ៨៦ ទំព័រប៉ុណ្ណោះ ហើយមិនមានចែងនូវជំពូកដោយឡែកមួយសម្រាប់អង្គច្បាប់ដែលថ្លែងអំពីអ្វីដែល កសព ជឿថាជាច្បាប់ដែលអាចយកមកអនុវត្តនៅ អវតក នោះឡើយ[53]។ នៅក្នុងសំណុំរឿង ០០២ ដីកាសន្និដ្ឋានស្ថាពរគឺមានកម្រាស់ ៩៣១ទំព័រ។ លោក កាំង ហ្គេកអ៊ាវ បានឆ្លើយតបត្រឹម ១២ទំព័រ ទៅនឹងដីកាសន្និដ្ឋានស្ថាពរដែលមានកម្រាស់ ៨៦ទំព័រ។ ជាឧទាហរណ៍ ១ទំព័រនៃចម្លើយតបទល់នឹង ៧ ទំព័រនៃដីកាសន្និដ្ឋានស្ថាពរ។ ចម្លើយតបរបស់លោក អៀង សារី ស្មើទៅនឹង ១ទំព័រទល់នឹង ១៤ទំព័រដែលបានដាក់ដោយ កសព នៅក្នុងដីកាសន្និដ្ឋានស្ថាពរ ។ បើសិនជាគោលការណ៍នៃការប្រព្រឹត្តមកលើដោយស្មើភាពគ្នាចំពោះមុខច្បាប់ ត្រូវបានគេគោរពមែននោះ លោក អៀង សារី ត្រូវតែបានគេអនុញ្ញាតអោយដាក់ចម្លើយតបអោយបានសមាមាត្រទៅនឹងរឿងក្តីប្រឆាំងនឹងគាត់។

### គ. សេចក្តីសម្រេចដែលគេជំទាស់តវ៉ារំលោភបំពានសិទ្ធិលោក អៀង សារី ក្នុងការត្រៀមរៀបចំកិច្ចការពារក្តី

៣៧. សេចក្តីសម្រេចដែលគេជំទាស់តវ៉ា ផ្តល់នូវលទ្ធផលមិនគ្រាន់តែបដិសេធចោលនូវចម្លើយតបរបស់លោក អៀង សារី ប៉ុណ្ណោះទេ ប៉ុន្តែក៏បានបដិសេធនូវសិទ្ធិរបស់គាត់ដើម្បីចងក្រងបង្កើតនូវទិន្នន័យហើយបន្ទាប់មកត្រៀមរៀបចំកិច្ចការពារក្តី។ ក្រឡាបញ្ជីរបស់ កសចស បន្ទាប់ពីការណែនាំរបស់សហចៅក្រមស៊ើបអង្កេត[54] បានបដិសេធសូម្បីតែទទួលយកការដាក់ឯកសាររបស់មេធាវីការពារក្តី។ ចម្លើយតបគួរ <u>ជាដំបូង</u> ត្រូវបានដាក់នៅក្នុងសំណុំរឿង ហើយ<u>បន្ទាប់មក</u> កសចស អាចទាំងយកជាសំអាង ឬចេញសេចក្តីសម្រេចបដិសេធចោល ដោយសារការងាកចេញពីចំនួនទំព័រកំណត់

---

[52] សេចក្តីសម្រេចដែលគេជំទាស់តវ៉ា។

[53] វាមានចែងនៅក្នុងជំពូកមួយស្តីពីការកំណត់បទល្មើសទៅលើអង្គហេតុ ប៉ុន្តែមិនមែនជាជំពូកនិយាយពីអង្គច្បាប់តែឯងនោះទេ។ ដីកាសន្និដ្ឋានស្ថាពរនៅក្នុងសំណុំរឿង ០០២ មានចែងជាជំពូកមួយដោយឡែកដែលនិយាយពីច្បាប់ដែលយកមកអនុវត្ត ក៏ដូចជាជំពូកមួយស្តីពីការកំណត់បទល្មើសទៅលើអង្គហេតុដែរ។ *សូមមើល* ដីកាសន្និដ្ឋានស្ថាពរនៅក្នុងសំណុំរឿង ០០១។

[54] *សូមមើល* សេចក្តីសម្រេចដែលគេជំទាស់តវ៉ា។

(ទោះបីថា ដូចដែលបានពន្យល់ខាងលើ ការបដិសេធចោលនេះនឹងមិនគួរត្រូវបានអនុញ្ញាតអោយនៅក្នុងរឿងក្តីនេះក៏ដោយ ដោយសារតែបញ្ហាដែលថាវានឹងរំលោភលើសិទ្ធិជាមូលដ្ឋានរបស់លោក អៀង សារី ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌)។ ដូច្នេះការបដិសេធទាំងស្រុងក្នុងការដាក់ចម្លើយតបទៅក្នុងសំណុំរឿង រារាំងមេធាវីការពារក្តី មិនអោយចងក្រងបង្កើតនូវទិន្នន័យ ហើយតាមរយៈនេះសិទ្ធិរបស់លោក អៀង សារី ក្នុងការត្រៀមរៀបចំកិច្ចការពារក្តីត្រូវបានបដិសេធ ដោយរំលោភបំពានទៅលើរដ្ឋធម្មនុញ្ញកម្ពុជា[55] កិច្ចព្រមព្រៀងបង្កើត អវតក[56] ច្បាប់បង្កើត អវតក[57] ICCPR[58] និង UDHR[59] ។

៣៨. នៅតុលាការដទៃទៀត ដែលសន្មតថាមានយុត្តាធិការលើបទល្មើសស្រដៀងគ្នានឹង អវតក ដែរនោះ ស្ថាប័ន Registry (ការិយាល័យរដ្ឋបាល) ដែលមានផ្នែកសេវាគ្រប់គ្រងតុលាការ (CMS) ជាផ្នែកមួយដ៏សំខាន់ ត្រូវបានគេពិចារណាថា ជាសសរទ្រូងមួយដែលមិនអាចខ្វះបាននៃដំណើរការតុលាការយ៉ាងពិតប្រាកដ ដោយសារ អព្យាក្រឹតភាពរបស់ស្ថាប័ននេះ តាមរយៈស្ថាប័នដទៃទៀតរបស់តុលាការ។ នៅតុលាការទាំងនេះ ស្ថាប័ន Registry អាចមិនមែនបានត្រឹមតែបដិសេធដោយងាយៗ នូវការដាក់ឯកសារដោយភាគីមួយក្នុងចំណោមភាគីនានានោះទេ។ អង្គជំនុំជម្រះដែលកាត់សេចក្តីទៅលើរឿងវិវាទ បន្ទាប់មកអាចបដិសេធចោលនូវពាក្យសុំមួយ ឬសូម្បីតែសម្រេចមិនយកអំណះអំណាងនានាដែលមាននៅក្នុងពាក្យសុំនោះ មកធ្វើការពិចារណាទៀតផង ដោយសារតែអំណះអំណាងទាំងនោះអាចទាក់ទៅនឹងបញ្ហាផ្សេងដែលមិនទាក់ទង។ ការច្រានចោល ឬ ការបដិសេធមិនយកអំណះ អំណាងនានាមកធ្វើការពិចារណា មិនមានផលប៉ះពាល់ដល់ប្រតិសកម្មដកយកចេញនូវពាក្យសុំនោះពីក្នុងសំណុំរឿងមកវិញនោះទេ។

៣៩. វិធីសាស្ត្ររបស់ កសចស នៅក្នុងការណែនាំអោយក្រឡាបញ្ជីរបស់ខ្លួនមិនអោយទទួលយកនូវចម្លើយតបគឺ ជាការធ្វើឡើងហួសអំណាច (ultra vires) ដោយសារខ្លួនអះអាងថាមានយុត្តាធិការ

---

[55] រដ្ឋធម្មនុញ្ញកម្ពុជា មាត្រា ៣៨ ។

[56] កិច្ចព្រមព្រៀងបង្កើត អវតក មាត្រា ១៣(១) ។

[57] ច្បាប់បង្កើត អវតក មាត្រា ៣៥ថ្មី ។

[58] ICCPR, មាត្រា ១៤(៣) ។

[59] UCHR, មាត្រា ១១(១) ។

00598682



ទៅលើកិច្ចការរបស់ក្រឡាបញ្ជី[60]ដែលអព្យាក្រិត។ វាហាក់ដូចជាថា ក្រឡាបញ្ជីរបស់ កសចស ដោយបានធ្វើជាស្ពានមួយដែលភ្ជាប់ស្ថាប័នដាច់ដោយឡែកពីរគឺ CMS និង កសចស ការពិតគឺត្រូវបានណែនាំដោយមិនត្រឹមត្រូវដោយ សហចៅក្រមស៊ើបអង្កេត ដើម្បីបដិសេធចោលការដាក់ឯកសារ ដោយគ្រាន់តែថា ការដាក់ឯកសារមួយចំនួនអាចបង្កភាពស្មុគស្មាញ ដល់ដំណើរការធ្វើសេចក្តីសម្រេចរបស់ កសចស។ ការប្រើប្រាស់ដោយមិនត្រឹមត្រូវនូវក្រឡាបញ្ជី រំលោភបំពានមិនមែនត្រឹមតែសិទ្ធិរបស់លោក អៀង សារី ប៉ុណ្ណោះ ទេ ប៉ុន្តែថែមទាំងដល់សិទ្ធិរបស់ភាគីនានាដែលត្រូវបានចោទប្រកាន់នៅចំពោះមុខ អវតក ទៀតផង។

## V. សំណូមពរ

**អាស្រ័យហេតុនេះ** តាមហេតុផលដូចដែលបានបញ្ជាក់ពីខាងលើ មេធាវីការពារក្តីសូមស្នើដោយក្តីគោរពសុំឱ្យអង្គបុរេជំនុំជម្រះមេត្តា៖

ក. **ប្រកាសថាបណ្តឹងឧទ្ធរណ៍នេះ** អាចទទួលយកបានតាមវិធាន២១ ។

ខ. **បដិសេធ**សេចក្តីសម្រេចដែលគេជំទាស់តវ៉ា និង

គ. **បង្គាប់ថា** ចម្លើយតបត្រូវតែទទួលយកដោយក្រឡាបញ្ជីរបស់ កសចស, ដាក់បញ្ចូលទៅក្នុងសំណុំរឿង និងត្រូវបាន កសចស ទទួលមកពិចារណាជាមួយគ្នានឹងដីកាសន្និដ្ឋានស្ថាពរ។

សូមចៅក្រមអង្គបុរេជំនុំជម្រះទទួលយកបណ្តឹងឧទ្ធរណ៍នេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ៦ ខែកញ្ញា ឆ្នាំ២០១០

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**អាង ឧត្តម** **Michael G. KARNAVAS**

សហមេធាវីរបស់លោក **អៀង សារី**

---

[60] *សូមមើល* សេចក្តីណែនាំអនុវត្តដាក់ឯកសារ មាត្រា ១០(១)។